ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
រដ្ឋបាលជលផល

# សៀវភៅមេរៀនស្តីពី
# សហគ្រប់គ្រងធនធានជលផល

## សៀវភៅទី៥ : ការកសាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍



ខែសីហា ឆ្នាំ២០១៨

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប

# សៀវភៅមេរៀនស្ដីពីសហគ្រប់គ្រងធនធានជលផល

## សៀវភៅទី៥ : ការកសាងផែនការគ្រប់គ្រង កន្លែងនេសាទសហគមន៍

រៀបចំដោយ

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប

រដ្ឋបាលជលផល

**សេចក្តីថ្លែងអំណរគុណ**

រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចងក្រងសៀវភៅមេរៀននេះ ក្រោមការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារពិភពលោក។

សៀវភៅមេរៀនទាំងនេះគឺជាសមិទ្ធិផលរបស់គម្រោងការគ្រប់គ្រងធនធានទឹកចម្រុះ ទន្លេមេគង្គ - ដំណាក់កាលទី ៣ (M-IWRMP-III) "ការគាំទ្រការគ្រប់គ្រងធនធានជលផលនៅភូមិភាគឦសាននៃប្រទេសកម្ពុជា" ដែលអនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប។

**ចងក្រងដោយ**

រូបឺត៍ ផមរ៉យ អេរិក បារ៉ាន ទូច គឹមឆាន សូខន សាវុទ្ធ លី វុទ្ធី ទុយ សមរាំ ឈួន ឡា
សូ រ័ត្នថាវី ផា ស្រួយ ប៊ុន រ៉ាសុី ទូច ប៊ុនថង ឆេង ផែន និង អេង ជាសាន។

**ជំនួយការ**

ស៊ឹម ថាវរី អ៊ូ សារី ជៀង សីហា ភូ សុខ ទិត្យ ពុទ្ធារ័ត្ន ប៉ុស ចាន់ណារ៉ា
កែន ឡៃហ៊ាង ភាជន៍ ឧស្សាហ៍ ទឹម សណ្តាន និងគូររូបដោយ ហេង សន្ធា។

សូមថ្លែងអំណរគុណដល់អ្នកជំនាញការ និងទីប្រឹក្សានៃធនាគារពិភពលោកដែលបានផ្តល់នូវមតិ និងកែលម្អ។

**ISBN-13: 978-9924-9278-1-5**

**គុណកថាបង្អែក**

រដ្ឋបាលជលផល (២០១៨). សៀវភៅបណ្តុះបណ្តាលស្តីពីការសហការគ្រប់គ្រងជលផល សៀវភៅទី៥: ការកសាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។ រដ្ឋបាលជលផល និងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប
រាជធានីភ្នំពេញ ប្រទេសកម្ពុជា ៣៦ទំព័រ។

**អាសយដ្ឋានទំនាក់ទំនង**

រដ្ឋបាលជលផល

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប

អាគារលេខ ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា

គេហទំព័រ ifredi-cambodia.org

**© រដ្ឋបាលជលផល (២០១៨)**

រក្សាសិទ្ធិ។ ការបោះពុម្ពឡើងវិញទាំងស្រុង ឬផ្នែកណាមួយសម្រាប់គោលបំណងអប់រំ ឬមិនរកប្រាក់ចំណេញ ដោយមិនចាំបាច់សុំការអនុញ្ញាតពីម្ចាស់ដើម និងគ្រាន់តែថ្លែងអំណរគុណដល់ប្រភពដើមត្រូវបានអនុញ្ញាត។ រាល់ការបោះពុម្ព ការចម្លង ឬចែកចាយសម្រាប់ធ្វើពាណិជ្ជកម្មត្រូវសុំការអនុញ្ញាតពីរដ្ឋបាលជលផល។

គ្រប់មតិ និងគំនិតទាំងអស់ជាទស្សនៈរបស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងពីរដ្ឋបាលជលផល ដៃគូ ស្ថាប័នគាំទ្រគម្រោង និងការបោះពុម្ពសៀវភៅនេះ។

# មាតិកា


១. សេចក្តីផ្តើម ........ ១
២. គោលបំណងនៃផែនការគ្រប់គ្រង ........ ២
៣. ព័ត៌មានជំហានទាំង៥ដែលរួមចំណែកការរៀបចំផែនការគ្រប់គ្រង ........ ៤
៣.១ ការវាយតម្លៃពីតម្រូវការ ........ ៥
៣.២ ការផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋ ........ ៧
៣.៣ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ........ ៨
៣.៤ ការកំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍ ........ ៩
៣.៥ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ........ ១០
៤. មាតិកាសំខាន់ៗនៃផែនការគ្រប់គ្រង ........ ១១
៤.១ ផ្នែកទី១៖ ទស្សនៈវិស័យ ........ ១២
៤.២ ផ្នែកទី២៖ ការកំណត់បញ្ហា និងការគំរាមកំហែង ........ ១៣
៤.៣ ផ្នែកទី៣៖ ការចាត់អាទិភាពបញ្ហា ការគំរាមកំហែង និងនិងតម្រូវការ ........ ១៦
៤.៣.១ ការចាត់អាទិភាពបញ្ហា និងការគំរាមកំហែង ........ ១៦
៤.៣.២ ការកំណត់ និងចាត់អាទិភាពតម្រូវការ ........ ១៨
៤.៤ ផ្នែកទី៤៖ គោលដៅផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ១៩
៤.៥ ផ្នែកទី៥៖ គោលបំណង និងសូចនាករ ........ ២១
៤.៥.១ គោលបំណង ........ ២១
៤.៥.២ សូចនាករ ........ ២២
៤.៦ ផ្នែកទី៦៖ វិធានការគ្រប់គ្រង ........ ២៤
៤.៦.១ វិធានការគ្រប់គ្រងការនេសាទ ........ ២៤
៤.៦.២ វិធានការពាក់ព័ន្ធនឹងវិស័យផ្សេងទៀត ........ ២៥
៤.៦.៣ ការរៀបចំវិធានការ ........ ២៧
៤.៧ ផ្នែកទី៧៖ ការគោរពច្បាប់ និងការពង្រឹងការអនុវត្តច្បាប់ ........ ២៩
៤.៨ ផ្នែកទី៨៖ ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងធនធានជលផល ........ ៣១
៤.៩ ផ្នែកទី៩៖  ការផ្សព្វផ្សាយ ........ ៣៣

៤.១០ ផ្នែកទី១០៖ សកម្មភាពយេនឌ័រ..........................................................................៣៤

៤.១១ ផ្នែកទី១១៖ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ....................................................៣៥

៥. ការសន្និដ្ឋាន..........................................................................................................៣៦

# ១. សេចក្តីផ្តើម

វគ្គបណ្តុះបណ្តាលនេះ មានគោលបំណងឱ្យសមាជិកសហគមន៍នេសាទចេះកសាងផែនការគ្រប់គ្រង ឬធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រង។ ក្រុមបច្ចេកទេសផ្តល់នូវ៖

- ខ្លឹមសារមេរៀនដែលមានរៀបរាប់លម្អិតអំពីជំហាននីមួយៗ
- សេចក្តីណែនាំអំពីការរៀបចំផ្នែកនីមួយៗ

ចំពោះសហគមន៍នេសាទដែលមានផែនការគ្រប់គ្រងរួចហើយ ត្រូវពិនិត្យឡើងវិញចំណុចខ្លះៗនៃផែនការគ្រប់គ្រង។ អ្នកសម្របសម្រួលចំណាយពេល ២ ឬ៣ម៉ោងសម្រាប់សហគមន៍នេសាទនីមួយៗ។

## គន្លឹះសម្រាប់អ្នកសម្របសម្រួល

វគ្គបណ្តុះបណ្តាលនេះ មានគោលបំណងឱ្យសមាជិកសហគមន៍នេសាទចេះកសាងផែនការគ្រប់គ្រង ឬធ្វើបច្ចុប្បន្នភាព។ ខ្លឹមសារមេរៀនរៀបរាប់លម្អិតអំពីជំហាននីមួយៗ ឧទា. ដូចជាលទ្ធផល និងរបៀប សរសេរលទ្ធផលនីមួយៗ។ កិច្ចការនេះពិនិត្យឡើងវិញនូវជំហានខ្លះៗដូចជាការបង្កើតទស្សនៈវិស័យ និងការប៉ាន់ប្រមាណតម្រូវការជាដើម។

ជំហាននៃដំណើរការកសាងផែនការរួមមាន៖ ការកំណត់ការគំរាមកំហែង បញ្ហា គោលដៅ គោលបំណង សូចនាករ យុទ្ធសាស្រ្ត ការគោរពច្បាប់ និងការពង្រឹងការអនុវត្តច្បាប់ ផែនការថវិកា ការផ្សព្វផ្សាយ យេនឌ័រ និងតាមដានត្រួតពិនិត្យ និងវាយតម្លៃ។

ការកសាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍មានភាពស្មុគស្មាញ អ្នកសម្របសម្រួលត្រូវចំណាយពេលប្រហែល២ ឬ៣ម៉ោងសម្រាប់សហគមន៍នេសាទនីមួយៗ។

## ២. គោលបំណងនៃផែនការគ្រប់គ្រង

គោលបំណងនៃការរៀបចំផែនការគ្រប់គ្រងគឺកំណត់នូវ៖

- គោលដៅ គោលបំណង យុទ្ធសាស្ត្រ និងសកម្មភាព
- តួនាទី និងភារកិច្ចរបស់សមាជិកសហគមន៍នេសាទ និងស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាល។

នៅក្នុងផែនការគួរបញ្ចូល៖

- បញ្ហាបរិស្ថាន៖ (ឧទា. ផលប៉ះពាល់លើជម្រកពងកូន កូនត្រីតូចៗ)
- បញ្ហាសង្គម៖ (ឧទា. វិវាទ សុខភាព សុវត្ថិភាព និងការកែច្នៃផលនេសាទ)
- បញ្ហាអភិបាលកិច្ច៖ (ឧទា. ដំណើរការពិគ្រោះយោបល់ និងការចូលរួមរបស់ស្ត្រី)

គណៈកម្មការសហគមន៍នេសាទសម្របសម្រួលដំណើរការកសាងផែនការ ប៉ុន្តែត្រូវកៀរគរការចូលរួមឱ្យបានទូលំទូលាយ។ ខណ្ឌរដ្ឋបាលជលផលជាអ្នកផ្តល់ជំនួយផ្នែកបច្ចេកទេស។

គណៈកម្មការសហគមន៍នេសាទត្រូវអញ្ជើញក្រុមស្ត្រីឱ្យចូលរួមដំណើរការកសាងផែនការ និងត្រូវបញ្ចូលបញ្ហា និងតម្រូវការរបស់ស្ត្រីទៅគ្រប់ទិដ្ឋភាពនៃផែនការ។

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវរៀបចំខ្លីៗ ដោយមិនមានពាក្យបច្ចេកទេស និងមានកម្រាស់ប្រហែល១៥ទំព័រ។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

យោងតាមប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ៖ ក្រោយពីចុះហត្ថលេខាលើកិច្ចព្រមព្រៀងកន្លែងនេសាទ សហគមន៍ត្រូវកសាងផែនការសម្រាប់គ្រប់គ្រងដែននេសាទរបស់ខ្លួន។

ផែនការគ្របដណ្តប់លើខ្លឹមសារមួយចំនួន៖

- បញ្ហាបរិស្ថាន (ឧទា. ផលប៉ះពាល់លើជម្រកពងកូនត្រីតូចៗ ចាប់ត្រីច្រើនពេក ចរាចរណ៍ផ្លូវទឹក និងចាប់កូនត្រីតូចៗ ...)
- បញ្ហាសង្គម (ឧទា. ការនេសាទខុសច្បាប់ វិវាទ ជម្រើសជីវភាពរស់នៅ សុខភាព សុវត្ថិភាពសមាជិកសហគមន៍ និងការកែច្នៃផលនេសាទរបស់ក្រុមស្ត្រី...)
- បញ្ហាអភិបាលកិច្ច (ឧទា. ដូចជាដំណើរការពិគ្រោះយោបល់ ការសម្រេចចិត្ត ការគ្រប់គ្រងហិរញ្ញវត្ថុ ការចូលរួមរបស់ស្ត្រី និងជនជាតិដើមភាគតិច...)

ខណ្ឌរដ្ឋបាលជលផលផ្តល់ជំនួយបច្ចេកទេស តាមការស្នើសុំជាលាយល័ក្ខអក្សររបស់សហគមន៍នេសាទ។

គ្រប់ជំហាននៃការកសាងផែនការ ត្រូវបញ្ចូលនូវទស្សនៈយេនឌ័រ ដូចជា បញ្ហា តម្រូវការ និងឱកាសរបស់ស្ត្រី។

## ៣. ព័ត៌មានដែលរួមចំណែកការរៀបចំផែនការគ្រប់គ្រង

ព័ត៌មានបានពីជំហានចំនួន៥នៃជំហានទាំង៩នៃការបង្កើតសហគមន៍នេសាទសម្រាប់កសាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។ ជំហានទាំង៥នោះរួមមាន៖

- ជំហានទី២៖ ការវាយតម្លៃអំពីតម្រូវការ
- ជំហានទី៣៖ ការផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋ
- ជំហានទី៤៖ ការរៀបចំលក្ខន្តិកៈ និងបទបញ្ញាផ្ទៃក្នុង
- ជំហានទី៦៖ ការកំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍
- ជំហានទី៧៖ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍




### គន្លឹះសម្រាប់អ្នកសម្របសម្រួល

អ្នកសម្របសម្រួល ត្រូវមានឯកសារ ស្តីពីការសិក្សាលទ្ធភាពបង្កើតសហគមន៍នេសាទ ការកំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍ ដោយដឹកនាំការពិភាក្សាជាមួយអ្នកចូលរួមធ្វើការឆ្លុះបញ្ចាំងចំណេះដឹង និងបទពិសោធន៍របស់ពួកគាត់។

អ្នកសម្របសម្រួលដឹកនាំពិភាក្សាអំពីការផ្សព្វផ្សាយបំផុស ក្នុងអំឡុងពេលបង្កើតសហគមន៍នេសាទ។

## ៣.១ ការវាយតម្លៃពីតម្រូវការ

ការវាយតម្លៃពីតម្រូវការរួមមានការកំណត់បញ្ហាដែលសហគមន៍ជួបប្រទះ និងរកដំណោះស្រាយ ធ្វើឱ្យប្រសើរឡើងជាងមុនៈ

- បញ្ហាបរិស្ថានសំខាន់ៗៈ (ឧទា. ភាពរាំងស្ងួត និងទឹកជំនន់ ...) និងដំណោះស្រាយ
- បញ្ហាសេដ្ឋកិច្ចសង្គមៈ (ឧទា. ការប្រកួតប្រជែងដើម្បីប្រមូលយកធនធាន កម្លាំងពលកម្មដែលមាន អ្នកផ្លាស់ទីលំនៅចេញចូលសហគមន៍) និងដំណោះស្រាយ
- បញ្ហាច្បាប់ទម្លាប់ និងស្ថាប័ន ដែលទាក់ទងនឹងវិស័យជលផលៈ (ឧទា. ភារកិច្ចជាន់គ្នារវាងស្ថាប័នពាក់ព័ន្ធ ភាពជាម្ចាស់ សិទ្ធិកាន់កាប់ និងអាស្រ័យផល) និងតម្រូវការជាអាទិភាព ដែលពាក់ព័ន្ធនឹងបញ្ហាទាំងនោះ
- បញ្ហាចម្បងៗពាក់ព័ន្ធនឹងធនធានជលផល (ភាពសម្បូរ ភាពចម្រុះនៃពូជត្រី និងពូជត្រីក្រៅស្រុក) ក៏ដូចជាបញ្ហាវិស័យជលផល (ការលួចនេសាទនៅកន្លែងហាមឃាត់ និងការប្រើឧបករណ៍នេសាទខុសច្បាប់...) និងការចាត់អាទិភាព។

ការវាយតម្លៃតម្រូវការនេះ បានកសាងជាប្រព័ន្ធនៅក្នុងផែនការគ្រប់គ្រង។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

ការវាយតម្លៃធ្វើរួចរាល់ក្នុងជំហានទី២នៃការបង្កើតសហគមន៍នេសាទ។ សហគមន៍នេសាទអាចធ្វើបច្ចុប្បន្នភាពផែនការរបស់ខ្លួននៅត្រង់ចំណុចនេះ។

ជំហានទី២នៃដំណើរការរៀបចំសហគមន៍នេសាទ មានការប្រមូលទិន្នន័យបឋម និងទិន្នន័យបន្ទាប់បន្សំ និងវិភាគព័ត៌មាន។ ព័ត៌មានអាចមានលក្ខណៈជាបរិមាណ ឬជាគុណវិស័យ និងលក្ខណៈដោយឡែក( ឧទា.ប្រជាពលរដ្ឋក្នុងភូមិ) ព្រមទាំងលក្ខណៈវិទ្យាសាស្ត្រ( ឧទា. ផែនទីទាញចេញពីអ៊ិនធ័រណែត) ឬផ្អែកតាមចំណេះដឹងពីមូលដ្ឋាន (ឧទា. ត្រីផ្លាស់ទីតាមរដូវ)។ ការសម្រេចចិត្តអំពីភាពលម្អិតនៃការប៉ាន់ប្រមាណ (ការសិក្សាលទ្ធភាពបង្កើតសហគមន៍) គឺអាស្រ័យនឹងតម្រូវការព័ត៌មានធនធាន និងពេលវេលា។

នៅផ្នែកនេះ អ្នកសម្របសម្រួលត្រូវរកឱ្យឃើញនូវឫសគល់ និងឯកភាពទៅលើបញ្ហាចម្បងៗមុនពេលរកបានដំណោះស្រាយ និងកំណត់បានសកម្មភាពសំខាន់ៗ។ ក្នុងករណីថវិកា និងធនធានមានកម្រិត សហគមន៍នេសាទត្រូវការចាត់អាទិភាពសកម្មភាព និងដំណោះស្រាយ។

តាមរយៈការចូលរួមរបស់សហគមន៍ នៅក្នុងជំហាននៃការសិក្សាលទ្ធភាពបង្កើតសហគមន៍ដំណើរការនេះក្លាយជាការផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋ ការអប់រំ និងការប្តេជ្ញាចិត្តដែលនាំឱ្យសកម្មភាពផ្សេងទៀតមានភាពរីកចម្រើន។

## ៣.២ ការផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋ

*ការផ្សព្វផ្សាយបំផុស*ប្រជាពលរដ្ឋមាននៅគ្រប់ជំហាននៃការកសាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

ការផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋ គឺជាការផ្តល់អំណាចឱ្យប្រជានេសាទ ដើម្បីឱ្យគាត់ទទួលបានចំណេះដឹង សម្រាប់ចូលរួមក្នុងដំណើរការគ្រប់គ្រងធនធានជលផល។ អ្នកសម្របសម្រួលត្រូវលើកទឹកចិត្តដល់ក្រុមស្ត្រី និងជនជាតិដើមភាគតិចឱ្យចូលរួមក្នុងសកម្មភាពរបស់សហគមន៍នេសាទ។

សមាជិកសហគមន៍នេសាទដែលមានការយល់ដឹង មានលទ្ធភាពបំពេញតួនាទីយ៉ាងសកម្មក្នុងដំណើរការគ្រប់គ្រងធនធានជលផលដូចជា៖ សម្របសម្រួលកិច្ចប្រជុំ ធ្វើជាតំណាង និងចូលរួមដោះស្រាយវិវាទជាដើម។

ប្រជាពលរដ្ឋដែលមានការយល់ដឹង មានលទ្ធភាពបំពេញតួនាទីជាពលរដ្ឋសកម្មក្នុងការចូលរួមគ្រប់គ្រងធនធាន ដោះស្រាយវិវាទ បង្កើនការយល់ដឹងអំពីធនធានជលផល និងការគ្រប់គ្រងផ្តោតលើប្រព័ន្ធអេកូឡូស៊ី។



## គន្លឹះសម្រាប់អ្នកសម្របសម្រួល

ទន្ទឹមនឹងប្រជាពលរដ្ឋមានការយល់ដឹង និងបារម្ភអំពីធនធានជលផល និងបរិស្ថាន តែក៏នៅមានអ្នកខ្លះមិនទាន់យល់ច្បាស់ ដែលជាហេតុនាំឱ្យការកសាងផែនការមានការលំបាក។ ដូចនេះត្រូវផ្សព្វផ្សាយការយល់ដឹងពីព័ត៌មានបច្ចេកទេសស្តីពីធនធានជលផល និងប្រពន្ធ័អេកូឡូស៊ីបន្ថែមទៀត ព្រមទាំងអភិវឌ្ឍន៍សមត្ថភាពប្រជានេសាទឱ្យចូលរួមយ៉ាងសកម្ម នៅក្នុងដំណើរការកសាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

## ៣.៣ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង

លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងត្រូវបានរៀបចំឡើងនៅពេលបង្កើតសហគមន៍នេសាទ ដែលមានការរៀបរាប់អំពីនីតិវិធីរដ្ឋបាល កំណត់ដំណើរការសហគមន៍នេសាទ សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិក។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

លក្ខន្តិកៈ ជានីតិវិធីរដ្ឋបាល ដែលកំណត់ពីរបៀបនៃការបង្កើតសហគមន៍នេសាទ និងដំណើរការរបស់វា (ការកត់ត្រា ការបោះឆ្នោតគណៈកម្មការសហគមន៍នេសាទ។ល។)

បទបញ្ញាផ្ទៃក្នុង គឺរៀបរាប់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់សមាជិក និងការងាររបស់សហគមន៍នេសាទ (ដូចជាកិច្ចប្រជុំជាដើម)។

## ៣.៤ ការកំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍

ផែនទីសហគមន៍ចាំបាច់ត្រូវរៀបចំដើម្បីកំណត់ឱ្យបានជាក់លាក់នូវផ្ទៃដី សម្រាប់ជាមូលដ្ឋាននៃការរៀបចំបទបញ្ញាផ្ទៃក្នុងសហគមន៍នេសាទដើម្បីអនុវត្តតាម។ កិច្ចការទាំងនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍។

ព្រំប្រទល់កន្លែងនេសាទសហគមន៍ត្រូវបង្ហាញទំនាក់ទំនងទៅវិញទៅមករវាងៈ

- ជម្រកវារីសត្វ និងលក្ខខណ្ឌបរិស្ថាន
- ភាពចម្រុះ ភាពសម្បូរ របាយពូជវារីសត្វ និងធនធានជលផល
- លក្ខណៈនៃការប្រើប្រាស់ធនធាន។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

ជាគំនិត ព្រំប្រទល់ដែននេសាទសហគមន៍ ត្រូវតែស្របជាមួយនឹងលក្ខណៈប្រពន្ធ័អេកូឡូស៊ី។ ទោះជាយ៉ាងនេះក្តី ក្នុងការអនុវត្តជាក់ស្តែងកន្លែងនេសាទសហគមន៍ត្រូវគិតគូរអំពីបរិបទសេដ្ឋកិច្ច សង្គម និងនយោបាយ។

កន្លែងនេសាទសហគមន៍ ត្រូវរៀបចំឱ្យមានវិសាលភាពសមស្រប ក្នុងការឆ្លើយតបនឹងតម្រូវការផ្នែកនយោបាយ សង្គម វប្បធម៌ និងប្រពន្ធ័អេកូឡូស៊ី។

## ៣.៥ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

យោងតាមប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ ជំពូកទី៨ ប្រការ២១ចែងថា៖ ឯកសារនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ត្រូវភ្ជាប់ជាមួយនូវ៖

- ផែនទី (មាត្រដ្ឋាន ១/៥០០០០) បង្ហាញពីទំហំកន្លែងនេសាទសហគមន៍ ដោយមានប្រព័ន្ធកូអ័រដោនេ(អាប់ស៊ីសនិងអ័រដោនេ) ច្បាស់លាស់
- បញ្ជីឈ្មោះសមាជិកសហគមន៍ និងគណៈកម្មការសហគមន៍នេសាទ
- ឯកសារលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង
- លិខិតស្នើដែលបញ្ជាក់ពីគោលបំណងបង្កើតសហគមន៍នេសាទ

**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ គឺជាកិច្ចព្រមព្រៀងស្របតាមច្បាប់ ដែលរដ្ឋបាលជលផល ផ្ទេរដែននេសាទទៅឱ្យសហគមន៍គ្រប់គ្រងប្រកបដោយនិរន្តរភាពក្នុងរយៈពេល៣ឆ្នាំ។ នៅក្នុងកិច្ចព្រមព្រៀងមានបញ្ជាក់ពីតួនាទី និងកាតព្វកិច្ចរបស់សហគមន៍នេសាទក្នុងការគ្រប់គ្រងធនធានជលផល និងតួនាទីរបស់ខណ្ឌរដ្ឋបាលជលផលក្នុងការគាំទ្រសហគមន៍នេសាទ ព្រមទាំងនីតិវិធីបន្ត និងបញ្ឈប់កិច្ចព្រមព្រៀង។

## ៤. មាតិកាសំខាន់ៗនៃផែនការគ្រប់គ្រង

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រួមមាន១១ផ្នែក៖

- **ទស្សនៈវិស័យ៖** រៀបរាប់ពីទស្សនៈយូរអង្វែងក្នុងពេលអនាគតរបស់សហគមន៍នេសាទ
- **ការកំណត់បញ្ហា ការគំរាមកំហែង និងតម្រូវការ៖** កំណត់បញ្ហា និងការគំរាមកំហែង ពាក់ព័ន្ធដែលត្រូវដោះស្រាយ
- **ការចាត់អាទិភាពនៃបញ្ហា និងការគំរាមកំហែង៖** ចាត់ថ្នាក់បញ្ហាដែលត្រូវដោះស្រាយ តាមលំដាប់លំដោយ
- **គោលដៅ៖** គោលដៅដែលយើងចង់សម្រេចបាន ដែលមានការពាក់ព័ន្ធនឹងបញ្ហាដែលត្រូវដោះស្រាយ
- **គោលបំណង សូចនាករ៖** ពាក់ព័ន្ធនឹងប្រពន្ធ័អេកូឡូស៊ី ធនធានផលផល និងប្រជាពលរដ្ឋ
- **វិធានការ៖** គឺជាសកម្មភាពដែលបានឯកភាពគ្នាដើម្បីសម្រេចគោលបំណងផ្អែកតាមធនធានដែលមាន និងពេលវេលាកំណត់
- **ការគោរព និងពង្រឹងការអនុវត្តច្បាប់៖** យន្តការដែលបញ្ជាក់អំពីអ្នកទទួលបន្ទុកអនុវត្តវិធានការពង្រឹងការអនុវត្តច្បាប់ និងការផាកពិន័យ
- **ហិរញ្ញវត្ថុ៖** កំណត់ពីប្រភព និងយុទ្ធសាស្ត្រកៀរគរថវិកាឱ្យមាននិរន្តរភាព
- **ការផ្សព្វផ្សាយ៖** យុទ្ធសាស្ត្រទំនាក់ទំនងរវាងសមាជិកសហគមន៍នេសាទ
- **សកម្មភាពយេនឌ័រ៖** សកម្មភាពនានាក្នុងការលើកកម្ពស់ស្ថានភាពស្ត្រី
- **ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ៖** ការវាយតម្លៃការគ្រប់គ្រង

**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

នេះជាការណែនាំពីព័ត៌មាន ត្រូវដាក់បញ្ចូលក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

## ៤.១ ផ្នែកទី១÷ ទស្សនៈវិស័យ

ផ្នែកទី១នៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍គឺ "ទស្សនៈវិស័យ"។

**ទស្សនៈវិស័យ** គឺជាប្រយោគមួយដែលរៀបរាប់សង្ខេបអំពីស្ថានភាពជាទូទៅដែលសហគមន៍នេសាទចង់បាននៅពេលអនាគតជាក់លាក់។

ឧទា. នៅឆ្នាំ២០៣០ ធនធានជលផលមានស្ថានភាពប្រព័ន្ធអេកូឡូស៊ីល្អ និងផ្តល់ផលប្រយោជន៍ ប្រកបដោយសមធម៌ដល់ប្រជានេសាទ តាមរយៈកិច្ចសហការ និងការគ្រប់គ្រងធនធានជលផលស្របតាមច្បាប់។

តើសហគមន៍នេសាទរបស់អ្នកមានទស្សនៈវិស័យយ៉ាងណា?

ទស្សនៈវិស័យ គ្របដណ្តប់ទៅលើគោលដៅ គោលបំណង សកម្មភាព និងផលប្រយោជន៍ដែលបានមកពីផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។ សហគមន៍ត្រូវចែករំលែកព័ត៌មានបច្ចេកទេស អំពីធនធានជលផល និងប្រព័ន្ធអេកូឡូស៊ី ដល់ប្រជាពលរដ្ឋក្នុងភូមិ ជាពិសេសដល់ក្រុមជនជាតិដើម
ភាគតិច។ការងារនេះជួយបង្កើនសមត្ថភាពប្រជាពលរដ្ឋឱ្យចូលរួមសកម្មក្នុងការងារសហគមន៍នេសាទ និងជួយពង្រឹងសហគមន៍ឱ្យមានប្រសិទ្ធភាព។ សហគមន៍នេសាទត្រូវលើកទឹកចិត្តស្ត្រី ឱ្យចូលរួមការងារសហគមន៍នេសាទ។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

ទស្សនៈវិស័យ រៀបរាប់អំពីអ្វី ដែលសមាជិកសហគមន៍នេសាទចង់បាននៅពេលអនាគត ឬជាលទ្ធផលដែលពួកគេចង់បានសម្រេចតាមរយៈសកម្មភាពសហគមន៍នេសាទ។

ឧទា. នៅ២០ឆ្នាំខាងមុខ ទិន្នផលត្រីមាននិរន្តរភាព សម្រាប់គ្រួសារនៃសហគមន៍នេសាទ ឬសហគមន៍នេសាទរបស់យើងក្លាយជាសហគមន៍គំរូមួយ ដែលអាចយកទៅអនុវត្តនៅកន្លែងផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា។

សារសំខាន់នៃការលើកកម្ពស់ការផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋគឺការចែករំលែកព័ត៌មានក្នុង និងក្រៅសហគមន៍នេសាទ ជាពិសេសក្រុមស្ត្រី និងក្រុមជនជាតិដើមភាគតិចដែលអាចឱ្យពួកគេមានលទ្ធភាពចូលរួមគ្រប់គ្រងធនធាន ដោះស្រាយបញ្ហាសេដ្ឋកិច្ចសង្គម និងតម្រូវការ។ កិច្ចការនេះជួយបង្កើនការយល់ដឹងអំពីធនធានជលផល និងការគ្រប់គ្រងក្នុងប្រពន្ធ័អេកូឡូស៊ី។

## ៤.២ ផ្នែកទី២៖ ការកំណត់បញ្ហា និងការគំរាមកំហែង

នៅផ្នែកទី២នៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍គឺ "ការកំណត់បញ្ហា និងការគំរាមកំហែង" ។ នៅផ្នែកនេះ ការកំណត់បញ្ហាមានដូចខាងក្រោម៖

- បរិស្ថាន៖ ឧទា. កិច្ចការពារ និងស្តារជម្រកត្រី កាត់បន្ថយការបំពុល និងគ្រប់គ្រងកាកសំណល់ និងធនធានជលផល
- សង្គម៖ ឧទា. សុវត្ថិភាពស្បៀង ការចិញ្ចឹមជីវិតដែលមាននិរន្តរភាព និងរចនាសម្ព័ន្ធជនបទជាដើម
- អភិបាលកិច្ច៖ ឧទា. ការចូលរួម ការផ្តល់សិទ្ធិអំណាច និងស្ថាប័នពាក់ព័ន្ធ

ក្រៅពីការកំណត់បញ្ហាដែលទាក់ទងនឹងវិស័យជលផល គេត្រូវកំណត់ផងដែរ នូវការអភិវឌ្ឍសហគមន៍ ការចិញ្ចឹមជីវិត សុវត្ថិភាពស្បៀង រចនាសម្ព័ន្ធជនបទ អភិបាលកិច្ច សេដ្ឋកិច្ច សង្គមកិច្ច និងប្រព័ន្ធអេកូឡូស៊ី។

សហគមន៍នេសាទត្រូវកំណត់បញ្ហា និងការគំរាមកំហែង ដែលត្រូវដោះស្រាយ។ នៅចំណុចនេះ យើងត្រូវគិតគូរពី៖

- បញ្ហាបរិស្ថាន៖ អំពីជម្រកត្រី
- បញ្ហាសង្គម៖ ផលលំបាករបស់សមាជិកសហគមន៍នេសាទ ដែលទាក់ទងនឹងធនធានជលផល
- អភិបាលកិច្ច៖ ចំណុចត្រូវកែលម្អ ដែលទាក់ទងនឹងទំនាក់ទំនងសង្គម។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

ផ្នែកនេះគឺធ្វើបច្ចុប្បន្នភាពលើព័ត៌មានដែលបានប្រមូលនៅក្នុងជំហានទី២នៃការរៀបចំសហគមន៍នេសាទ។ កិច្ចការនេះ នឹងកំណត់ពីហេតុនៃបញ្ហា មុននឹងកំណត់ដំណោះស្រាយដើម្បីអនុវត្ត។

ជំហានដំបូងសមាជិកសហគមន៍នេសាទត្រូវកំណត់បញ្ហាចម្បងៗដែលជាក្តីកង្វល់របស់ពួកគាត់។ បន្ទាប់មកត្រូវរកឱ្យឃើញបញ្ហា ការគំរាមកំហែង និងតម្រូវការជាក់លាក់ ដែលទាក់ទងនឹងវិស័យជលផល និងបញ្ហាក្រៅពីវិស័យជលផល (ឧទា. ការបំពុលនៅតំបន់ខ្ពង់រាប) និងបញ្ហាសង្គម (ឧទា. ការតាំងទីលំនៅថ្មី) ជាដើម។

ជាការប្រសើរ ការកំណត់បញ្ហា ការគំរាមកំហែង និងដំណោះស្រាយឱ្យបានល្អត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំ ឬសិក្ខាសាលាដោយអញ្ជើញសមាជិកចូលរួមឱ្យបានច្រើន។ បើសិនជាមានអ្នកចូលរួមតិច បញ្ហាមួយចំនួនមិនអាចកំណត់ឱ្យបានគ្រប់ជ្រុងជ្រោយ ហើយការទទួលខុសត្រូវ និងភាពជាម្ចាស់របស់ប្រជាពលរដ្ឋគឺមានកម្រិត។

ដំណើរការដែលធ្វើឱ្យអ្នកចូលរួមមានការចាប់អារម្មណ៍ គឺប្រើសម្ភារជំនួយ រូបភាពលើក្តារខៀន ឬលើក្រដាស និងរូបត្ថុក។ ដំបូងត្រូវចាប់ផ្តើមពីបញ្ហាទូទៅ និងបន្ទាប់មក ជជីកសួររកបញ្ហាជាក់លាក់ដែលមានទំនាក់ទំនងជាមួយនឹងដំណោះស្រាយ។ គេអាចប្រើវិធីសាស្ត្រដើមឈើបញ្ហា ដែលដើមឈើគឺជាបញ្ហាចម្បង ឯឫសគឺហេតុនៃបញ្ហា និងមែកធាងជាផលវិបាកដែលកើតចេញពីបញ្ហា ដែលត្រូវចាត់អាទិភាព។

## ៤.៣ ផ្នែកទី៣៖ ការចាត់អាទិភាពបញ្ហា ការគំរាមកំហែង និងនិងតម្រូវការ

### ៤.៣.១ ការចាត់អាទិភាពបញ្ហា និងការគំរាមកំហែង

បន្ទាប់ពីកំណត់បញ្ហារួច យើងត្រូវចាត់អាទិភាពបញ្ហាតាមលំដាប់លំដោយ។ នៅពេលចាត់អាទិភាពបញ្ហា ត្រូវពិចារណាអំពី៖

- លទ្ធភាពដែលបញ្ហាអាចកើតមានឡើង
- ការជះឥទ្ធិពលរបស់បញ្ហា
- លទ្ធភាពក្នុងការដោះស្រាយបញ្ហា (សកម្មភាពរបស់សហគមន៍នេសាទ)

ការដាក់ពិន្ទុអាចមានពី០ ទៅ៥ ៖

- ហានិភ័យ៖ ពិន្ទុ ០ មានន័យថាហានិភ័យទាប ពិន្ទុ ៥ ហានិភ័យខ្ពស់
- ឥទ្ធិពល៖ ពិន្ទុ ០ មានន័យថាឥទ្ធិពលទាប ពិន្ទុ ៥ ឥទ្ធិពលខ្ពស់
- សកម្មភាពដោះស្រាយ៖ ពិន្ទុ ០ គឺគ្មានដំណោះស្រាយ ពិន្ទុ ៥ ដោះស្រាយបានល្អ

ឧទា.៖

| | លទ្ធភាពដែលបញ្ហាអាចកើតឡើង | ឥទ្ធិពលរបស់វា | សកម្មភាពដោះស្រាយ | សរុប |
|---|---|---|---|---|
| ទីតាំងភូមិនៅឆ្ងាយពីទីផ្សារ | ៤ | ៤ | ១ | ៩ |
| ស្ត្រីគ្មានពេលចូលរួមការងារសហគមន៍ | ៣ | ៣ | ៣ | ៩ |
| ប្រជាពលរដ្ឋធ្វើចំណាកស្រុកទៅទីក្រុង | ២ | ២ | ១ | ៥ |
| ការបូមបាចបឹងនៅរដូវប្រាំង | ៥ | ៤ | ៤ | ១៣ |
| គ្មានប្រាក់ឧបត្ថម្ភដល់សកម្មភាពគ្រប់គ្រងធនធានជលផល | ៥ | ៥ | ៣ | ១៣ |
| គ្មានថវិកាសម្រាប់ការងារល្បាត | ៥ | ៣ | ៤ | ១២ |
| សហគមន៍នេសាទមិនអាចពិន័យជនល្មើស | ៥ | ៣ | ២ | ១០ |

**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

នៅពេលកំណត់បញ្ហា និងការគំរាមកំហែង សហគមន៍នេសាទរកឃើញបញ្ហាជាច្រើន ប៉ុន្តែមានតែបញ្ហាមួយចំនួនប៉ុណ្ណោះ ដែលអាចដោះស្រាយបាន។ ដោយសារតែធនធានមានកំណត់ ដូច្នេះតម្រូវឱ្យមានការចាត់អាទិភាពបញ្ហា។

បើសិនជាអាច យើងជ្រើសរើសយកវិធីមួយ ដែលអាចដោះស្រាយបានបញ្ហាភាគច្រើន ហើយចាំបាច់ត្រូវចាត់អាទិភាពបញ្ហា និងរៀបចំបញ្ហាទៅតាមក្រុម៖ បរិស្ថាន សង្គម និង
អភិបាលកិច្ច។

បញ្ហាដែលមានអាទិភាពខ្ពស់ គឺជាបញ្ហាដែលទំនងជាកើតឡើង និងមានឥទ្ធិពលធ្ងន់ធ្ងរ។

ឧទា. ហានិភ័យចំពោះបញ្ហាមួយ៖

- តើបញ្ហាមួយនេះអាចទំនងជាកើតឡើងឬទេ? (លទ្ធភាព)
- តើមានផលវិបាកអ្វីខ្លះ បើសិនជាមានបញ្ហានេះកើតឡើង? (ផលវិបាក)
- តើយើងមានវិធានការអ្វីខ្លះ ដើម្បីកាត់បន្ថយឥទ្ធិពលនៃបញ្ហានេះ? (សកម្មភាព)

## ៤.៣.២ ការកំណត់ និងចាត់អាទិភាពតម្រូវការ

បន្ទាប់ពីកំណត់បញ្ហា ការគំរាមកំហែង និងចាត់អាទិភាពរួច ត្រូវកំណត់ និងចាត់អាទិភាពតម្រូវការ។ តម្រូវការត្រូវរៀបទៅតាមលំដាប់លំដោយ។ ការចាត់អាទិភាពអំពី៖

- តម្រូវការ និងអាទិភាពនៃបញ្ហាបរិស្ថាន៖ អំពីជម្រកត្រី
- តម្រូវការ និងអាទិភាពនៃបញ្ហាសង្គម៖ ដែលមានទំនាក់ទំនងនឹងវិស័យជលផល
- តម្រូវការ និងអាទិភាពនៃបញ្ហាអភិបាលកិច្ច។




**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

នៅពេលដែលបានកំណត់បញ្ហា និងការគំរាមកំហែង រួមទាំងការចាត់អាទិភាព សហគមន៍នេសាទត្រូវពិភាក្សារកឱ្យឃើញអ្វីដែលជាតម្រូវការ និងសកម្មភាពចម្បងៗដើម្បីឆ្លើយតបនឹងបញ្ហា និងការគំរាមកំហែងទាំងនោះ។

នៅក្នុងជំហានទី២ នៃវាយតម្លៃកំណត់ទីកន្លែងសម្រាប់បង្កើតសហគមន៍នេសាទ ដំណើរការនេះក្លាយជាការផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋ ការអប់រំ និងការប្តេជ្ញាចិត្ត ដែលនាំឱ្យសកម្មភាពផ្សេងទៀតមានដំណើរការ។

## ៤.៤ ផ្នែកទី៤÷ គោលដៅផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

នៅផ្នែកទី៤នៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍គឺចែងអំពី"គោលដៅនៃការគ្រប់គ្រង"។

**គោលដៅ** គឺជាការរៀបរាប់ទូទៅអំពីចំណុចដៅ ដែលសហគមន៍នេសាទនឹងអនុវត្ត (អ្វីដែលអាចនឹងសម្រេចបានពីការអនុវត្តសកម្មភាព)។

គោលដៅមានលក្ខខណ្ឌមួយចំនួនដូចជា៖

- *គំនិតស្រមៃ៖* ការរៀបរាប់ពីស្ថានភាពចង់បាន ហើយអ្នកពាក់ព័ន្ធនានាត្រូវនាំធ្វើឱ្យបានសម្រេច
- *ភាពទូទៅ៖* ប្រមូលផ្តុំគ្រប់សកម្មភាព
- *សង្ខេប៖* ខ្លីៗ និងងាយៗដែលអ្នកពាក់ព័ន្ធអាចចងចាំបាន
- *វាស់វែងបាន៖* អាចវាស់វែងភាពរីកចម្រើនបាន

ឧទា.៖

- ធនធានជលផលត្រូវបានស្តារឡើងវិញ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព
- ជម្រកត្រីដែលរងការបំផ្លិចបំផ្លាញ និងងាយរងគ្រោះត្រូវបានស្តារឡើងវិញ និងថែរក្សាត្រឹមត្រូវ



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

គោលដៅនៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវមានទំនាក់ទំនងជាមួយនឹងបញ្ហាការគំរាមកំហែង និងតម្រូវការដែលបានចាត់អាទិភាពរួច។

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ខ្លះមានគោលដៅមួយ ខ្លះមានគោលដៅច្រើន យកល្អគួរមានគោលដៅមួយជាការងាយស្រួល។

គោលដៅនីមួយៗ ដែលឆ្លើយតបនឹងបញ្ហា ឧបសគ្គ និងឱកាស អាស្រ័យនឹងការចំណាយការគាំទ្រនានា សមត្ថភាពអ្នកអនុវត្ត ពេលវេលា និងតម្រូវការផ្សេងៗ។

គោលដៅ គឺលម្អិតជាងទស្សនៈវិស័យ ព្រោះវារួមបញ្ចូលគ្នានៃដែនកំណត់ និងការលំបាក (ទស្សនៈវិស័យជាក្តីស្រមៃ )។

ទស្សនៈវិស័យ → គោលដៅ → គោលបំណង → សូចនាករ

**ទស្សនៈវិស័យ៖** ស្ថានភាពមួយដែលប្រាថ្នាឱ្យបានសម្រេច

**គោលដៅ៖** ចំណុចដៅរួម ដែលសហគមន៍នេសាទធ្វើសកម្មភាពនានា ដើម្បីបានសម្រេច

**គោលបំណង៖** ចំណុចដៅដែលត្រូវនឹងបញ្ហា និងការគំរាមកំហែងនីមួយៗ

**សូចនាករ៖** ជារង្វាស់សម្រាប់វាស់វែងភាពរីកចម្រើននៃការអនុវត្តផែនការ។

## ៤.៥ ផ្នែកទី៥÷ គោលបំណង និងសូចនាករ

### ៤.៥.១ គោលបំណង

ផ្នែកទី៥ នៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ គឺគោលបំណង និងសូចនាករ។

**គោលបំណង** គឺជាចំណុចដៅ ដែលត្រូវសម្រេចឱ្យបានក្នុងពេលអនាគត ដោយឆ្លើយតបនឹងបញ្ហានានា។

ឧទា. កាត់បន្ថយឥទ្ធិពលលើការនេសាទសត្វផ្សោត។

គោលបំណងអាចសម្រេចបានទៅតាមធនធានដែលមាន និងពេលវេលាកំណត់។ បញ្ហា និងការគំរាមកំហែងមួយ ត្រូវមានគោលបំណងមួយ ឬច្រើនអាស្រ័យនឹងអ្វីដែលយើងត្រូវសម្រេចឱ្យបាន។

គោលបំណងអាចមាន៖ ១) បរិស្ថានល្អ៖ ឧទា. ការស្តារឡើងវិញ និងការពារជម្រកពងកូន កាត់បន្ថយការបំពុល ការគ្រប់គ្រងកាកសំណាល់ និងធនធានជលផល ២) សុខុមាលភាព

ប្រជាពលរដ្ឋ៖ ឧទា. សុវត្ថិភាពស្បៀង ការចិញ្ចឹមជីវិតមាននិរន្តរភាព ហេដ្ឋារចនាសម្ព័ន្ធជនបទ និង ៣) អភិបាលកិច្ច៖ ឧទា. ការចូលរួម ការផ្តល់អំណាច និងការពង្រឹងស្ថាប័នជាដើម។

វិធីសរសេរគោលបំណងមានលក្ខណៈសំខាន់ៗដូចខាងក្រោម៖

- ច្បាស់លាស់ / ចំៗ
- អាចវាស់វែងបាន (លទ្ធផលធៀបនឹងសូចនាករ)
- ឯកភាពពីគ្រប់អ្នកពាក់ព័ន្ធភាគច្រើន
- ពិតប្រាកដ (អាចអនុវត្តបាន និងធនធានគ្រប់គ្រាន់)
- កំណត់ពេលវេលាជាក់លាក់សម្រាប់សកម្មភាពចម្បងៗ

ឧទា. គោលដៅរបស់សហគមន៍នេសាទគឺ " ស្តារឡើងវិញនូវផលត្រី "

គោលបំណង ៖ នៅឆ្នាំ២០២០ បង្កើនពពួកត្រីខ្មៅយ៉ាងតិច ចំនួន៣០% ប្រៀបធៀបនឹងឆ្នាំ២០១៨។

**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

គោលបំណង គឺជាការរៀបរាប់អំពីលទ្ធផលរំពឹងទុកដែលសហគមន៍នេសាទចង់បាន។ គោលបំណងការងាររបស់សហគមន៍នេសាទត្រូវតែមានទំនាក់ទំនងជាមួយនឹងគោលដៅ ឆ្លើយតបនឹងបញ្ហាដែលកំណត់ និងចាត់អាទិភាពដោយសមាជិកសហគមន៍នេសាទ។ ឧទា. បើសិនជាកំណកល្បាប់ក្រាស់ពេក វាជាការគំរាមកំហែងខ្លាំងដល់ជម្រកត្រី និងផលចាប់ ហេតុនេះគោលបំណងអាចជា៖ កាត់បន្ថយល្បាប់កក់ដែលហូរចាក់ទៅក្នុងទឹកទន្លេ។

ផែនការខ្លះមានគោលបំណងច្រើន និងខ្លះទៀតមានតិច ដែលអាចបំពេញគ្នាទៅវិញទៅមក។ បើសិនជាមានគោលបំណងច្រើន និងស្មុគស្មាញ ត្រូវបំបែកជាផ្នែកតូចៗ។ គោលបំណងអាចមានពីមួយទៅបី សម្រាប់បញ្ហាអាទិភាពនីមួយៗ។

## ៤.៥.២ សូចនាករ

ដើម្បីវាស់វែងលទ្ធផលនៃការសម្រេចគោលបំណង ត្រូវមាន**សូចនាករ**។

សូចនាករ សម្រាប់វាស់ស្ទង់ការងារគ្រប់គ្រង ថាតើបានសម្រេចគោលបំណងដែរឬទេ? នៅពេលដែលប្រៀបធៀបជាមួយនឹងចំណុចដៅ វានឹងបង្ហាញពីរបៀបដែលអ្នកគ្រប់គ្រងបំពេញការងារ។

សង្ខេប៖

ទស្សនៈវិស័យ → គោលដៅ → គោលបំណង → សូចនាករ

- *ទស្សនៈវិស័យ៖* ស្ថានភាពមួយដែលប្រាថ្នាឱ្យបានសម្រេច
- *គោលដៅ៖* ចំណុចដៅរួម ដែលសហគមន៍នេសាទធ្វើសកម្មភាពនានា ដើម្បីសម្រេចបាន
- *គោលបំណង៖* លទ្ធផលរំពឹងទុក ដែលត្រូវនឹងបញ្ហា និងការគំរាមកំហែងនីមួយៗ
- *សូចនាករ៖* សម្រាប់វាស់វែងភាពរីកចម្រើននៃការអនុវត្តផែនការ។

ការកំណត់គោលបំណង និងសូចនាករ ឱ្យទៅជាវិធានការគ្រប់គ្រងដូចបានរៀបរាប់លម្អិតខាងក្រោម៖

ទស្សនៈវិស័យ

→ គោលដៅ

→គោលបំណងទី១

→ សូចនាករទី១

→គោលបំណងទី២

→ សូចនាករទី២

→គោលបំណងទី៣

→ សូចនាករទី៣

ឧទា.៖

ទស្សនៈវិស័យ៖ *នៅឆ្នាំ២០៣០ ធនធានជលផលមាននិរន្តរភាព និងផ្តល់ផលប្រយោជន៍ដល់សមាជិកសហគមន៍នេសាទប្រកបដោយសមធម៌។*

គោលដៅ៖ *មានការការពារជម្រកវារីសត្វ និងត្រួតពិនិត្យផលចាប់ និងបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌។*

គោលបំណងទី១៖ *បញ្ឈប់ការបំផ្លាញជម្រកពងកូន*

- សូចនាករទី១ក៖ *នៅឆ្នាំ២០២០ គ្មានការបូមបាចបឹងយ៉ាងតិច ៤ ក្នុងចំណោម៦ នៅវដ្តវប្រាំង*
- សូចនាករទី១ខ៖ *នៅឆ្នាំ២០២០ គ្មានករណីបំពុលត្រីទៀត*

គោលបំណងទី២៖ *មានការត្រួតពិនិត្យ លើការធ្វើនេសាទ*

- សូចនាករទី២ក៖ *នៅឆ្នាំ២០២០ មានការកាត់បន្ថយបទល្មើសនេសាទ ៨០% បើប្រៀបធៀបនឹងឆ្នាំ២០១៨*
- សូចនាករទី២ខ៖ *នៅឆ្នាំ២០២០ ត្រីដែលប្រជានេសាទប្រមូលបាន មានបរិមាណដូចគ្នានឹង ឆ្នាំ២០១៨*

គោលបំណងទី៣៖ *មានការបែងចែកផលប្រយោជន៍ដែលផលនេសាទ ប្រកបដោយសមធម៌ក្នុងចំណោមសមាជិកសហគមន៍នេសាទ*

- សូចនាករទី៣៖ *នៅឆ្នាំ២០២០ សមាជិកសហគមន៍មិនលើស១០% តវ៉ាអំពីការបែងចែកផលប្រយោជន៍មិនស្មើគ្នា*

## ៤.៦ ផ្នែកទី៦÷ វិធានការគ្រប់គ្រង

### ៤.៦.១ វិធានការគ្រប់គ្រងការនេសាទ

ផ្នែកទី៦ នៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍គឺ "វិធានការគ្រប់គ្រង"។ សកម្មភាពគ្រប់គ្រង គឺជាបណ្តុំសកម្មភាពដែលអនុវត្តដើម្បីសម្រេចគោលបំណង។ វិធានការគ្រប់គ្រងការនេសាទរួមមាន៖

ការត្រួតពិនិត្យផលចាប់៖

- ផលចាប់សម្រាប់ អ្នកនេសាទម្នាក់ៗ (អាច២០គីឡូក្រាម / ម្នាក់ / សប្តាហ៍)
- ការកំណត់ទំហំត្រី និងប្រភេទត្រី ដែលត្រូវនេសាទ (ទំហំនៃប្រភេទនីមួយៗ)

ការត្រួតពិនិត្យអ្នកនេសាទ និងមធ្យោបាយនេសាទ៖

- ចំនួនអ្នកនេសាទ
- ចំនួនទូកកាណូត ទំហំ និងកម្លាំងសេះ
- ប្រភេទ និងទំហំឧបករណ៍នេសាទ
- ផលចាប់សម្រាប់អ្នកនេសាទម្នាក់ៗ (អាច២០គីឡូក្រាម / ម្នាក់ / សប្តាហ៍)

សកម្មភាពត្រូវហាមឃាត់៖

- ការបំពុល និងឧបករណ៍ឆក់ត្រី ...
- ការដាក់របាំងតាមព្រែក

ការត្រួតពិនិត្យកន្លែងនេសាទ៖

- ហាមឃាត់ការនេសាទក្នុងវត្តអារាម និងកន្លែងអភិរក្សត្រី
- កន្លែងហាមឃាត់ (ឧទា. គ្មានការនេសាទនៅកន្លែងត្រីពងកូន)

រដូវបិទ និងបើកនេសាទ៖

- រដូវបិទនេសាទ
- រដូវបើកនេសាទ

សិទ្ធប្រើប្រាស់៖

- ហាមធ្វើសន្និធិនៅខេត្តក្រចេះ និងស្ទឹងត្រែង

**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

ក្រោយពីឯកភាពលើគោលបំណង ត្រូវសម្រេចថាតើសកម្មភាពចម្បងៗអ្វីខ្លះដែលនឹងត្រូវអនុវត្ត ដើម្បីសម្រេចគោលបំណង? ទាំងអស់នេះគឺជាវិធានការគ្រប់គ្រង។

### ៤.៦.២ វិធានការពាក់ព័ន្ធនឹងវិស័យផ្សេងទៀត

វិធានការគ្រប់គ្រង មិនត្រឹមតែសំដៅដល់ការនេសាទប៉ុណ្ណោះទេ ប៉ុន្តែត្រូវគ្របដណ្តប់ទៅលើទិដ្ឋភាពបរិស្ថាន ទិដ្ឋភាពសង្គម និងអភិបាលកិច្ចទៀត។

វិធានការពាក់ព័ន្ធនឹងវិស័យផ្សេងទៀតរួមមាន៖

ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី

- តំបន់ការពារ (មិនអនុញ្ញាតនេសាទ)
- ការកែលម្អជម្រកត្រី (ឧទា. កំប្លោកដែលអាចជាជម្រកត្រី ប្រឡាយតូចៗដែលភ្ជាប់រវាងអូរស្ទឹង និងវាលស្រែ ឬជីកស្នាមភ្លោះក្នុងស្រែ
- ការស្តារជម្រកត្រីឡើងវិញ (ដាំបន្លែក្នុងស្រះ មិនប្រមូលបន្លែឬវារីជាតិទុកសម្រាប់ត្រីពងកូន និងរក្សាកម្ពស់ទឹកសមស្របនៅរដូវប្រាំង
- បង្កើនពូជត្រី (លែងពូជត្រីទៅក្នុងអាងធម្មជាតិ)
- កិច្ចការពារពូជត្រី ដែលកំពុងមានបញ្ហា ឧទា. ត្រីប៉ាសេអ៊ី ត្រីត្រសក់ ...

វិធានការសង្គម៖

- ជម្រើសនៃរបរចិញ្ចឹមជីវិត (បន្ថយសម្ពាធលើផលត្រី..អេកូទេសចរណ៍ និងការចិញ្ចឹមត្រី)
- ការបង្កើតហេដ្ឋារចនាសម្ព័ន្ធ បង្កើតផ្សារសម្រាប់អ្នកទិញលក់ត្រី
- ការអប់រំសាធារណជន និងអភិវឌ្ឍសមត្ថភាព
- ជំរុញការងាររកចំណូលរបស់ក្រុមស្ត្រី
- សមាហរណកម្មកិច្ចការផ្តល់ប្រយោជន៍ដល់ជនជាតិភាគតិចក្នុងភូមិ

វិធានការដែលពាក់ព័ន្ធវិស័យផ្សេងទៀត៖

- ការគ្រប់គ្រងធនធានទឹក
- ការគ្រប់គ្រងកសិកម្ម (កម្រិតនៃការប្រើប្រាស់ថ្នាំពុល)

- ការគ្រប់គ្រងព្រៃលិចទឹក (គ្រប់គ្រងព្រៃលិចទឹកសម្រាប់ត្រីពងកូន)
- ការគ្រប់គ្រងដី (ដំណាំបន្លែនៅតំបន់វាលទំនាប កម្រិតល្បប់ក្នុងស្រះ)
- ការសម្របទៅនឹងការប្រែប្រួលអាកាសធាតុ (ជួយដើម្បីកុំឱ្យពឹងផ្អែកតែទៅលើការនេសាទមួយមុខ)

វិធានការអភិបាលកិច្ចៈ

- កិច្ចសហការកាន់តែប្រសើរជាមួយនឹងរដ្ឋបាលជលផល
- ធ្វើសមាហរណកម្ម ជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល
- ការរៀនសូត្រជាប្រព័ន្ធពីភាពជោគជ័យ និងបរាជ័យនៃគម្រោងសាកល្បងពីសហគមន៍នេសាទនានា។

### ៤.៦.៣ ការរៀបចំវិធានការ

ដើម្បីសម្រេចគោលបំណងមួយ ត្រូវកំណត់សកម្មភាពចម្បងៗ។ ចង្កោមសកម្មភាពចម្បងៗ ហៅថា "**យុទ្ធសាស្ត្រគ្រប់គ្រង**"។

ឧទា.៖ គោលដៅ គោលបំណង សូចនាករ និងវិធានការ

| គោលដៅ | គោលបំណង | សូចនាករ | វិធានការ |
|---|---|---|---|
| ប្រើប្រាស់ផលត្រី ប្រកបដោយនិរន្តរភាព និងការពារពូជត្រី | ត្រួតពិនិត្យឧបករណ៍ខុសច្បាប់ | ០% នៃផលចាប់ ដោយឧបករណ៍ ហាមឃាត់ | ហាមឃាត់ការបំពុល គ្រឿងផ្ទុះ ឧបករណ៍ ឆក់និងបូមបាច |
| | ហាមធ្វើនេសាទប្រភេទត្រី ដែលត្រូវការពារ | អតិបរមា៥% នៃពូជ ត្រីត្រូវការពារ (ចំនួន និងទម្ងន់) | ១) ហាមនេសាទនៅ តំបន់អភិរក្ស ក.ខ.គ<br>២) លែងប្រភេទត្រី វិញ ពេលនេសាទបាន |

ក្នុងការជ្រើសរើសសកម្មភាពត្រូវពិចារណាអំពី៖

- លទ្ធភាពអនុវត្ត
- ភាពជោគជ័យ
- ការចំណាយ

ដើម្បីអនុវត្តវិធានការត្រូវបង្កើតផែនការសកម្មភាពដែលរៀបរាប់អំពី៖

- សកម្មភាពលម្អិត
- រយៈពេលដែលត្រូវអនុវត្ត
- អ្នកទទួលខុសត្រូវអនុវត្ត
- អ្នកចូលរួមអនុវត្ត។

| វិធានការ | សកម្មភាពលម្អិត | រយៈពេល | អ្នកទទួលខុសត្រូវ | អ្នកចូលរួម អនុវត្ត |
|---|---|---|---|---|
| ហាមបំពុល ឧបករណ៍ធក់ និង របាំងព្រួល | ហាមលក់ថ្នាំបំពុល និង ឧបករណ៍ធក់នៅទីផ្សារ ត្រួតពិនិត្យស្ថានភាព ម្តង/សប្តាហ៍ | ១ឆ្នាំ | លោក លោកស្រី ក | លោក លោកស្រី ច.ឆ.ជ |
| ១)ហាមនេសាទនៅ កន្លែង ក. ចំពោះពូជត្រី ដែលការពារ ក.ខ.គ | កំណត់កន្លែងហាម ឃាត់ គូរផែនទី ត្រួតពិនិត្យម្តង/សប្តាហ៍ | ២ឆ្នាំ | លោក លោកស្រី ខ | លោក លោកស្រី ច.ឈ.ញ |
| ២) លែងពូជត្រីកម្រ ទៅវិញពេលនេសាទ បាន | ត្រួតពិនិត្យត្រី លក់ដូរ នៅទីផ្សារ | ១ឆ្នាំ | លោក លោកស្រី គ | លោក លោកស្រី ធ.ប.ផ |

## ៤.៧ ផ្នែកទី៧÷ ការគោរពច្បាប់ និងការពង្រឹងការអនុវត្តច្បាប់

ផ្នែកទី៧ នៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍គឺការគោរព និងការពង្រឹងការអនុវត្តច្បាប់។

ការពង្រឹងការអនុវត្តច្បាប់រួមមាន វិធីសាស្ត្រច្រើនក្នុងការផ្លាស់ប្តូរផ្នត់គំនិតរបស់ជនល្មើស។ ការពង្រឹង ការអនុវត្តច្បាប់មានវិធីសាស្ត្រទន់ភ្លន់ និងវិធានការក្តៅ។

វិធានការទន់ភ្លន់រួមមាន៖

- ទិវាសំខាន់ៗ ឧទា.ទិវាមច្ឆជាតិ
- យុទ្ធនាការតស៊ូមតិ និងប្រមូលឧបករណ៍នេសាទខុសច្បាប់ដោយស្ម័គ្រចិត្ត
- សិក្ខាសាលា វេទិកាសាធារណៈ
- ទស្សនកិច្ចសិក្សា ការផ្លាស់ប្តូរបទពិសោធន៍
- ការបញ្ចូលក្នុងកម្មវិធីសិក្សា និងសម្តែងសិល្បៈ
- ការផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋ ក្រុមឃ្លាំមើល

វិធានការក្តៅរួមមាន៖

- ចុះល្បាតជាប្រចាំ
- សកម្មភាពស្វែងរកចាប់ខ្លួន និងបញ្ជូនទៅតុលាការ
- ដាក់ពិន័យទណ្ឌកម្មទៅតាមបទល្មើសជាក់ស្តែង

ផ្នែកនេះត្រូវរៀបរាប់អំពី ការពង្រឹងការអនុវត្តច្បាប់ដែលបញ្ជាក់អំពីអ្នកទទួលខុសត្រូវ មធ្យោបាយ និងទោសទណ្ឌសម្រាប់អ្នកបំពាន។

វិធានការគ្រប់គ្រង គួរកាត់បន្ថយ ឬធ្វើឱ្យផលប៉ះពាល់អវិជ្ជមានតិចបំផុតចំពោះសមាជិកសហគមន៍នេសាទ និងក្រុមភាគតិច។ ឧទា. បើសិនជាមានការហាមការនេសាទនៅតំបន់ណាមួយ ត្រូវគិតគូរពីសុវត្ថិភាព ដើម្បីធានាបានការអនុវត្តដោយយុត្តិធម៌ និងស្មើភាពចំពោះគ្រប់សមាជិក

សហគមន៍នេសាទទាំងអស់។ ចំពោះគ្រួសារណា ដែលរងឥទ្ធិពលអវិជ្ជមាន ពីការអនុវត្តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវផ្ដល់អាទិភាពក្នុងការទទួលបានថវិកាគាំទ្រដើម្បីប្រកបមុខរបរផ្សេង។

**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

វិធានការទន់ភ្លន់ជំរុញការអនុវត្តច្បាប់ដោយស្ម័គ្រចិត្ត និងមិនបញ្ជូនទៅតុលាការ។ វិធានការទន់ភ្លន់ផ្ដោតលើ៖ ក) ប្រជាពលរដ្ឋកាន់តែច្រើនចូលរួមគោរពច្បាប់ ខ) លើកទឹកចិត្តដល់ការអនុវត្តច្បាប់ដោយស្ម័គ្រចិត្ត និង គ) បង្កើនការបង្ការទុកជាមុន។

វិធានការតឹងរ៉ឹងដែលអនុវត្តដោយអាជ្ញាធរមានសមត្ថកិច្ច និងតុលាការ ដើម្បីឱ្យជនល្មើសរាងចាល។ វិធានការនេះមានគោលបំណងតែមួយគឺកំណត់ជនល្មើស កំណត់ទីតាំង និងបង្ក្រាបជនល្មើសដោយប្រើប្រាស់គ្រប់រូបភាពនៃទិដ្ឋភាពច្បាប់។

នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទមានការរៀបរាប់អំពីគោលការណ៍រាយការណ៍ និងទណ្ឌកម្មចំពោះការបំពាននានា ហើយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវបំពេញគ្នាទៅវិញទៅមកជាមួយនឹងបទបញ្ជាផ្ទៃក្នុង។

## ៤.៨ ផ្នែកទី៨៖ ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងធនធានជលផល

ផ្នែកទី៨ នៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ គឺការកៀរគរថវិកាសម្រាប់គ្រប់គ្រងជលផល។ ផែនការថវិការៀបចំឡើងដោយផ្អែកលើការចំណាយលើសកម្មភាពផ្សេងៗ។

ការគ្រប់គ្រងថវិការបស់សហគមន៍នេសាទរួមមាន៖

ការចំណាយសំខាន់ៗ៖

- ចំណាយហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារបរិក្ខារ (ទូកល្បាត និងទំនាក់ទំនង និងគូសព្រំប្រទល់)
- ចំណាយប្រតិបត្តិការ (ប្រេង អាហារ កិច្ចប្រជុំ...)
- ចំណាយការរៀបចំមុខរបរ ក្រៅពីនេសាទ

ចំណូលសំខាន់ៗ៖ ប្រភពមានខាងក្នុង និងខាងក្រៅ។ នៅពេលដែលសហគមន៍នេសាទ ពឹងផ្អែកទាំងស្រុងលើប្រភពខាងក្រៅនាំឱ្យមានឥទ្ធិពលមិនល្អដល់សហគមន៍នេសាទ។

ប្រភពខាងក្រៅ ៖

- អំណោយ (ឧទា. ភ្នាក់ងារផ្តល់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន)
- ចំណូលពីទេសចរណ៍ (ឧទា. ថ្លៃចូលទស្សនា វិភាគទានដោយស្ម័គ្រចិត្ត...)
- ចំណូលពីសិប្បកម្មខ្នាតតូច (ឧទា. ប្រហុកផ្អក ត្រីងៀត ត្បាញរវៃ វត្ថុអនុស្សាវរីយ៍ អាវយឺត ចម្លាក់...)
- ចំណូលពីក្រុមសន្សំ និងចំណូលពីផលនេសាទ

ផែនការចំណូល និងចំណាយ៖ ធ្វើយ៉ាងណាឱ្យមានថវិកាគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការ។



## គន្លឹះសម្រាប់អ្នកសម្របសម្រួល

ថវិកាមានសារសំខាន់ចំពោះផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងជាកត្តាគន្លឹះសម្រាប់សម្រេចបាននិរន្តរភាពរយៈពេលវែង។ ថវិកាត្រូវតែមានគ្រប់គ្រាន់ សម្រាប់ចំណាយប្រតិបត្តិការ ដែលទាក់ទងនឹងផែនការ ការអនុវត្ត ការសម្របសម្រួល តាមដានត្រួតពិនិត្យ និងការពង្រឹងការអនុវត្តច្បាប់។

យោងតាមប្រកាស ស្តីពីការណែនាំអំពីសហគមន៍នេសាទ សហគមន៍មួយអាចរកចំណូលស្របច្បាប់ពីប្រភពផ្សេងៗ និងគ្រប់គ្រងដោយខ្លួនឯង ដូចជាវិភាគទានរបស់សមាជិក អំណោយសប្បុរសជន។ គណៈកម្មការសហគមន៍នេសាទបើកគណនីធនាគារដើម្បីគ្រប់គ្រងថវិការបស់សហគមន៍ប្រកបដោយតម្លាភាព និងគណនេយ្យភាព។

ផែនការថវិកាត្រូវបានរៀបចំឡើង ដោយឈរលើការវាយតម្លៃចំណាយប្រតិបត្តិការ ចំពោះសកម្មភាពនៃផែនការគ្រប់គ្រងសហគមន៍នេសាទ។ សហគមន៍នេសាទត្រូវគិតពីដំបូង អំពីផែនការថវិកាដើម្បីឱ្យសហគមន៍មានដំណើរការទាំងរយៈពេលខ្លី និងរយៈពេលវែង។

ការណែនាំលម្អិតមានចែងនៅក្នុងគោលការណ៍ណែនាំស្តីពីការកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់បរិក្ខារ។

## ៤.៩ ផ្នែកទី៩៖ ការផ្សព្វផ្សាយ

ចំពោះសកម្មភាពចម្បងៗនៃផែនការត្រូវផ្សព្វផ្សាយជូនអ្នកពាក់ព័ន្ធ ជាពិសេសសមាជិកសហគមន៍នេសាទដែលរងផលប៉ះពាល់ផ្ទាល់។ ការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋបានល្អ សហគមន៍នេសាទត្រូវផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋអំពីផែនការ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃ ដើម្បីឱ្យការគោរពច្បាប់មានប្រសិទ្ធភាព និងចៀសវាងវិវាទ។

ផ្នែកទី៩នៃ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ គឺការផ្សព្វផ្សាយ។ ផ្នែកនេះរួមមាន៖

- សកម្មភាពសំខាន់ៗត្រូវផ្សព្វផ្សាយ
- ទីតាំង និងរបៀបធ្វើការផ្សព្វផ្សាយ
- ពេលវេលាដែលត្រូវផ្សព្វផ្សាយ

វិធីសាស្ត្រផ្សព្វផ្សាយអាចធ្វើឱ្យប្រសើរឡើងបានដោយផ្អែកតាមស្ថានភាពជាក់ស្តែង មតិយោបល់ និងសំណូមពររបស់អ្នកចូលរួម។

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ជាសាធារណៈអាចធ្វើឡើងបានតាមរយៈ៖

- ពេលមានបុណ្យភូមិ ឬក្នុងកិច្ចប្រជុំនានា
- ការចែកឯកសារសង្ខេបពីផែនការ
- ការរៀបចំបដា
- ការលើកស្លាកសញ្ញានៅតំបន់អភិរក្ស

ឯកសារផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវចម្លងជូន រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកខណ្ឌ រដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ។

## ៤.១០ ផ្នែកទី១០÷ សកម្មភាពយេនឌ័រ

ផ្នែកទី១០ នៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍គឺ "សកម្មភាពយេនឌ័រ" ។

នៅក្នុងភូមិមួយមានប្រជាពលរដ្ឋ៥០%ជាស្ត្រី និងកុមារី។ បុរស និងស្ត្រីមានបញ្ហា តម្រូវការ និងសមត្ថភាពខុសៗគ្នា ហេតុនេះនៅពេលកសាងផែនការត្រូវពិចារណាអំពីចំណុចទាំងអស់នេះ ដើម្បីឆ្លុះបញ្ចាំងអំពីទិដ្ឋភាពយេនឌ័រ។

យេនឌ័រ គឺជាការស្វែងយល់អំពីទំនាក់ទំនងរវាងបុរស និងស្ត្រី

ផែនការសកម្មភាពយេនឌ័ររួមមាន៖

- ការរៀបចំការងារដើម្បីដោះស្រាយបញ្ហាយេនឌ័រ
- ការកំណត់គោលដៅជាក់លាក់ក្នុងការដាក់បញ្ចូលបញ្ហាស្ត្រីទៅក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- គោលបំណង សកម្មភាពចម្បងៗ សូចនាករ និងអ្នកទទួលខុសត្រូវអនុវត្ត ដើម្បីធានាការចូលរួមរបស់ស្ត្រី និងធានាថាក្រុមស្ត្រីទទួលបានផលប្រយោជន៍ពិតៗ ពីការអនុវត្តផែនការ
- សូចនាករអំពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើទិដ្ឋភាពយេនឌ័រ

ឧទា. ផែនការសកម្មភាពយេនឌ័រ

| គោលបំណង | សកម្មភាព | សូចនាករ | អ្នកទទួលខុសត្រូវ អនុវត្ត |
|---|---|---|---|
| ធានាថាមានចំនួនស្ត្រីនៅក្នុងគណៈកម្មការសហគមន៍នេសាទ | លើកទឹកចិត្តស្ត្រីចូលរួមកិច្ចប្រជុំរបស់សហគមន៍នេសាទជំរុញឱ្យស្ត្រីឈរឈ្មោះជាសមាជិកគណៈកម្មការ | ចំនួនស្ត្រីដែលជាសមាជិកគណៈកម្មការចូលរួមកិច្ចប្រជុំយ៉ាងតិច ២៥% | ប្រធានគណៈកម្មការ |

**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

ទស្សនៈយេនឌ័រសំដៅដល់តួនាទី និងទំនាក់ទំនង ឥរិយាបថ និងគុណតម្លៃ អត្តចរិក និងអាកប្បកិរិយា ដែលសង្គមកំណត់រវាងបុរស និងស្ត្រី។ យេនឌ័រ គឺជាការស្វែងយល់អំពីភាពខុសគ្នារវាងបុរស និងស្ត្រី នៅពេលដែលភេទទាំង២រវាងបុរស និងស្ត្រីមានជីវសាស្ត្រខុសគ្នា។ តួនាទីយេនឌ័រមានភាពខុសគ្នាទៅតាមវប្បធម៌នីមួយៗ និងអាចផ្លាស់ប្តូរគ្រប់ពេលវេលា។ យេនឌ័រគឺការគិតគូរអំពីទំនាក់ទំនងរវាងបុរស និងស្ត្រី។ បុរស ស្ត្រី កុមារា កុមារីមានបញ្ហា តម្រូវការ និងសមត្ថភាពខុសៗគ្នា។

## ៤.១១ ផ្នែកទី១១÷ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដានត្រួតពិនិត្យ ត្រូវធ្វើឡើងនៅពេលដែលយើងចង់ដឹងថា ការអនុវត្តផែនការមានភាពរលូនដែរឬទេ? ចំណែកឯការវាយតម្លៃ ត្រូវធ្វើឡើងនៅពេលដែលយើងចង់ដឹងថា ការអនុវត្តផែនការមានភាពជោគជ័យ ឬបរាជ័យ និងទទួលបានបទពិសោធន៍ដូចម្តេច? ដូចនេះការគ្រប់គ្រងអាចកែសម្រួលបានទៅតាមស្ថានភាពជាក់ស្តែង។

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍មានបង្ហាញអំពីគោលបំណង សូចនាករ ហើយការតាមដាន ត្រួតពិនិត្យផ្តល់ព័ត៌មានចាំបាច់ ដែលត្រូវវាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តការងារគ្រប់គ្រង។ ការវាយតម្លៃ រួមមានការពិនិត្យមើលលទ្ធផលដែលអនុវត្ត និងវាយតម្លៃអំពីសកម្មភាព និងលទ្ធផលសម្រេចបានចុងក្រោយ? វាគឺជាមេរៀន និងបទពិសោធន៍ សម្រាប់កែលម្អឱ្យប្រសើរឡើង

ដើម្បីតាមដានត្រួតពិនិត្យ និងវាយតម្លៃ លើសូចនាករ យើងត្រូវការព័ត៌មានជាក់លាក់ បន្ទាប់ពីការអនុវត្តផែនការ ។ ទិន្នន័យគោល គួរត្រូវបានប្រមូល បន្ទាប់ពីកំណត់សូចនាករ ។

ការតាមដានត្រួតពិនិត្យ និងវាយតម្លៃគួរបញ្ចូល៖

- ទស្សនៈយេនឌ័រ ដែលផ្តោតការយកចិត្តទុកដាក់លើបញ្ហា និងតម្រូវការរបស់ស្ត្រី និងកុមារី
- ទស្សនៈអំពីក្រុមជនជាតិដើមភាគតិច ក្រុមងាយរងគ្រោះក្នុងភូមិ ដើម្បីទទួលបានព័ត៌មានជាក់លាក់អំពីបញ្ហា ការគំរាមកំហែង និងឆ្លើយតបតាមតម្រូវការរបស់ពួកគាត់
- កាលបរិច្ឆេទសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ។

**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ គឺជាដំណើរការពិនិត្យឡើងវិញ និងវាយតម្លៃ ដើម្បីឱ្យដឹងថាតើសកម្មភាព និងវិធានការដែលដាក់ចេញត្រូវបានអនុវត្តមានប្រសិទ្ធភាពដែរឬទេ? តើមានសកម្មភាពអ្វីខ្លះទៀតដែលត្រូវអនុវត្តបន្ត?

ការតាមដានត្រួតពិនិត្យ ត្រូវឆ្លើយនឹងសំណួរ៖ តើយើងកំពុងធ្វើដូចម្តេច?

ការវាយតម្លៃ ត្រូវឆ្លើយនឹងសំណួរ៖ តើយើងបានធ្វើដូចម្តេច?

នៅពេលដែលឆ្លើយនឹងសំណួរទាំងនេះ នឹងជួយយើងឱ្យមានការកែលម្អសកម្មភាពនានាតាមរយៈការរៀនសូត្រពីបទពិសោធន៍។

ការតាមដានត្រួតពិនិត្យ និងវាយតម្លៃគឺត្រូវការព័ត៌មាន ដើម្បីប៉ាន់ប្រមាណអំពីវឌ្ឍនភាព និងការប្រែប្រួល។

ការតាមដានត្រួតពិនិត្យ និងវាយតម្លៃល្អអាចជួយកែសម្រួលផែនការទៅតាមស្ថានភាពជាក់ស្តែងបានប្រសើរឡើង។ "ការរៀនសូត្រពីបទពិសោធន៍។

## ៥. ការសន្និដ្ឋាន

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវរៀបចំឡើងតាមមាតិកាខាងលើ។

នៅពេលដែលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ព្រាងរួច ត្រូវដាក់បង្ហាញដល់សមាជិកសហគមន៍នេសាទ ដើម្បីពិនិត្យឡើងវិញ និងកែសម្រួលតាមការចាំបាច់ ដោយកត់ត្រានូវមតិយោបល់របស់អ្នកចូលរួម។ បន្ទាប់ពីកែសម្រួល ត្រូវដាក់សុំការអនុម័តចុងក្រោយ។

ក្រោយពីបានរៀបចំសេចក្តីព្រាងផែនការរួច គណៈកម្មការសហគមន៍នេសាទត្រូវថតចម្លង និងផ្ញើទៅរដ្ឋបាលជលផលថ្នាក់កណ្តាល តាមរយៈខណ្ឌរដ្ឋបាលជលផល ដើម្បីសុំការពិនិត្យ និងឯកភាព។ បើសិនជាមានការកែសម្រួល ខណ្ឌរដ្ឋបាលជលផលត្រូវពិនិត្យមើលជារៀងរាល់ឆ្នាំ ដើម្បីរាយការណ៍ទៅរដ្ឋបាលជលផលថ្នាក់កណ្តាល។

សុពលភាពនៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ស្មើគ្នានឹងសុពលភាពនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍។

## សារតារ

គម្រោង "ការគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ - ដំណាក់កាលទី៣" ទទួលបានមូលនិធិពីធនាគារពិភពលោក។ គោលបំណងគម្រោង គឺដើម្បីបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងធនធានទឹក និងការគ្រប់គ្រងធនធានជលផលប្រកបដោយប្រសិទ្ធភាព នៅភាគឦសាននៃប្រទេសកម្ពុជា។ សមាសភាគទី ១ (ការគ្រប់គ្រងធនធានជលផលនៅភាគឦសាននៃប្រទេសកម្ពុជា) គ្រប់គ្រងដោយរដ្ឋបាលជលផល និងអនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប។ គោលបំណងនៃសមាសភាគទី១គឺដើម្បីកែលម្អការគ្រប់គ្រងធនធានជលផលនៅក្នុងតំបន់គោលដៅដែលបានជ្រើសរើសនៅក្នុងខេត្តក្រចេះ និងស្ទឹងត្រែង។

### សៀវភៅមេរៀនចំនួន៥ ស្តីពីសហគ្រប់គ្រងធនធានជលផល

សៀវភៅមេរៀននេះគឺជាផ្នែកមួយនៃសៀវភៅមេរៀនជាស៊េរីចំនួន៥ ស្តីពីសហគ្រប់គ្រងជលផលនៅកម្ពុជា។ សៀវភៅមេរៀនទាំងនេះ សម្រាប់ភូមិដែលមានបំណងចង់បង្កើតសហគមន៍នេសាទ សមាជិកសហគមន៍នេសាទ សមាជិកគណៈកម្មការសហគមន៍នេសាទ និងមន្ត្រីខណ្ឌរដ្ឋបាលជលផល។

*សៀវភៅទី១: ការបង្កើតសហគមន៍នេសាទសហគមន៍*
*ក្រុមគោលដៅ: អ្នកភូមិ*
*សៀវភៅទី២: ការពង្រឹងសមត្ថភាពសហគមន៍នេសាទ*
*ក្រុមគោលដៅ: សមាជិកសហគមន៍នេសាទ*
*សៀវភៅទី៣: ការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ*
*ក្រុមគោលដៅ: សមាជិកគណៈកម្មាការសហគមន៍នេសាទ*
*សៀវភៅទី៤: ការពង្រឹងសមត្ថភាពខណ្ឌរដ្ឋបាលជលផល*
*ក្រុមគោលដៅ: បុគ្គលិករដ្ឋបាលជលផល*
***សៀវភៅទី៥: ការកសាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍***
*ក្រុមគោលដៅ: សមាជិកសហគមន៍នេសាទ*
*ជាពិសេសសមាជិកគណៈកម្មាការសហគមន៍នេសាទ*

រដ្ឋបាលជលផល
វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប
អាគារលេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ប្រទេសកម្ពុជា
គេហទំព័រ ifredi-cambodia.org

9 789924 927815